ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា សម្រាប់កិច្ចដំណើរការរបស់ក្រុមបណ្ឌិតសភាចារ្យ និងជាសេនាធិការនៃការស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា។

ជំពូកទី២
តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន

មាត្រា២.-

លេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីជាសេនាធិការអចិន្ត្រៃយ៍ សម្រាប់កិច្ចដំណើរការរបស់ក្រុមបណ្ឌិតសភាចារ្យ និងជាយន្តការសម្របសម្រួលក្នុងកិច្ចការស្រាវជ្រាវវិទ្យាសាស្ត្ររវាងក្រុមបណ្ឌិតសភាចារ្យជាមួយនឹងវិទ្យាស្ថាននានារបស់រាជបណ្ឌិត្យសភាកម្ពុជា។

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចខាងក្រោម៖

-រៀបចំផែនការការងារនិងសម្របសម្រួលការងារទូទៅជូនក្រុមបណ្ឌិតសភាចារ្យ

-រៀបចំយន្តការដើម្បីជំរុញការងារស្រាវជ្រាវ បកប្រែ បោះពុម្ពផ្សាយ និង ការងារវិទ្យាសាស្ត្រ

-រៀបចំការប្រជុំវិទ្យាសាស្ត្រដើម្បីពិគ្រោះយោបល់អំពីព្រឹត្តិការណ៍សំខាន់ៗរបស់ជាតិនិងអន្តរជាតិ

-រៀបចំសន្និសីទ សិក្ខាសាលា វេទិកាបណ្ឌិតសភា និង វេទិកាវិទ្យាសាស្ត្រនានា

-គ្រប់គ្រងការងាររដ្ឋបាល និង ទំនាក់ទំនងសាធារណៈជូនក្រុមបណ្ឌិតសភាចារ្យ

-សហការ ជំរុញ និងទទួលបន្ទុកការងារបើកផ្តល់ថវិកាឧបត្ថម្ភនិងថវិកាស្រាវជ្រាវ ព្រមទាំងការងារហិរញ្ញវត្ថុជូនក្រុមបណ្ឌិតសភាចារ្យ និងមន្ត្រីក្រោមឱវាទ

-គ្រប់គ្រងការងារសោតទស្សន៍ និងការងារផ្សព្វផ្សាយ

-រៀបចំរបាយការណ៍អំពីសកម្មភាពនិងសមិទ្ធផលការងារ ជូនក្រុមបណ្ឌិតសភាចារ្យ

-រៀបចំរបាយការណ៍របស់ក្រុមបណ្ឌិតសភាចារ្យជូនប្រមុខរាជរដ្ឋាភិបាល

-រៀបចំនិងបណ្តុះបណ្តាលធនធានមនុស្សរបស់លេខាធិការដ្ឋាន ដើម្បីពង្រឹងប្រសិទ្ធភាពនិងបង្កើនសមត្ថភាពនិងគុណភាពការងារ

-ទទួលអនុវត្តការងារផ្សេងៗទៀតដែលក្រុមបណ្ឌិតសភាចារ្យប្រគល់ជូន។

ជំពូកទី៣
ការគ្រប់គ្រងនិងកិច្ចដំណើរការ

មាត្រា៣.-

លេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធានចំនួន២(ពីរ)រូប។ ការបំពេញភារកិច្ចរបស់អនុប្រធានម្នាក់ៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជបណ្ឌិត្យសភាកម្ពុជា តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន។

www.pheakdeylaw.com

មាត្រា៤.-

ប្រធាននិងអនុប្រធានលេខាធិការដ្ឋាន ជាមន្ត្រីនៃរាជបណ្ឌិត្យសភាកម្ពុជា ហើយត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រុមបណ្ឌិតសភាចារ្យ។

មាត្រា៥.-

បទបញ្ជាផ្ទៃក្នុង សម្រាប់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជបណ្ឌិត្យសភាកម្ពុជា។

មាត្រា៦.-

មន្ត្រីលេខាធិការដ្ឋាន ជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ដែលមានចំណេះដឹងនិងសមត្ថភាពខ្ពស់ និងមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។

មាត្រា៧.-

មន្ត្រីលេខាធិការដ្ឋាន ដែលជាជំនួយការផ្ទាល់របស់បណ្ឌិតសភាចារ្យម្នាក់ៗ ត្រូវស្ថិតនៅក្រោមខ្សែបណ្តោយផ្ទាល់ជាមួយក្រុមបណ្ឌិតសភាចារ្យ និងស្ថិតនៅក្រោមខ្សែទទឹងនៃការគ្រប់គ្រងរដ្ឋបាលរបស់លេខាធិការដ្ឋាន។

មាត្រា៨.-

មន្ត្រីលេខាធិការដ្ឋាន ត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តបន្ថែម តាមការកំណត់របស់រាជរដ្ឋាភិបាល។

មាត្រា៩.-

មន្ត្រីលេខាធិការដ្ឋាន ត្រូវទទួលការវាយតម្លៃអំពីគុណភាពនិងប្រសិទ្ធភាពការងារប្រចាំឆ្នាំ។ នីតិវិធី និងយន្តការនៃការវាយតម្លៃនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជបណ្ឌិត្យសភាកម្ពុជា។

មាត្រា១០.-

ការចំណាយសម្រាប់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិកា ក្រោមខ្ទង់ថវិការបស់រាជបណ្ឌិត្យសភាកម្ពុជា នៅក្នុងក្របខណ្ឌថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

លេខាធិការដ្ឋាន មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាន និងមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា១១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

www.pheakdeylaw.com

មាត្រា១២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមបណ្ឌិតសភាចារ្យ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com